**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..........០២២/១៤..........ក.ប/ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការរៀបចំយន្តការសម្រាប់
# កសាងសេចក្តីព្រាងច្បាប់ស្តីពីតុលាការការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ-បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងលិខិតលេខ ៩២៤ សជណ.អវ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងស្មារតីអង្គប្រជុំពិភាក្សាការងារស្តីពីសេចក្តីព្រាងច្បាប់ស្តីពីតុលាការការងារ កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការរៀបចំយន្តការសម្រាប់កសាងសេចក្តីព្រាងច្បាប់ស្តីពីតុលាការការងារដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- **ឯកឧត្តម អ៊ិត សំហេង** | រដ្ឋមន្ត្រី | ប្រធាន |
| ២- **ឯកឧត្តម អ៊ុំ មាន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- **ឯកឧត្តម ម៉ម វណ្ណៈ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤- **ឯកឧត្តម សាត សមុទ្រ** | អនុរដ្ឋលេខាធិការ | សមាជិក |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

| | | |
|---|---|---|
| ៥- **ឯកឧត្តម ហ៊ី ទុឡ្សី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៦- **ឯកឧត្តម ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៧- **ឯកឧត្តម សេង សក្ដា** | អគ្គនាយកការងារ | សមាជិក |

**ប្រការ២.-**

គណៈកម្មការរៀបចំយន្តការសម្រាប់កសាងសេចក្ដីព្រាងច្បាប់ស្ដីពីតុលាការការងារនេះ មានក្រុមការងារកសាងខ្លឹមសារ និងឯកសារមួយជាជំនួយការដែលមានសមាសភាព និងតួនាទីភារកិច្ចដូចខាងក្រោម ៖

ក-សមាសភាព៖

| | | |
|---|---|---|
| ១- **ឯកឧត្តម ម៉ម វណ្ណៈ** | រដ្ឋលេខាធិការ | ប្រធាន |
| ២- **ឯកឧត្តម សាត សមុទ្រ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- **ឯកឧត្តម ហ៊ី ទុឡ្សី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤- **ឯកឧត្តម ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- **ឯកឧត្តម សេង សក្ដា** | អគ្គនាយកការងារ | អនុប្រធាន |
| ៦- **ឯកឧត្តម ហុង ជឿន** | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | អនុប្រធាន |
| ៧- **លោក អ៊ិន ខេមរា** | អគ្គនាយករងការងារ | សមាជិក |
| ៨- **លោក ជួប ណារ៉ាត់** | អគ្គនាយករងការងារ | សមាជិក |
| ៩- **លោក អ៊ុក សមវិទ្យា** | នាយកបេឡាជាតិរបបសន្តិសុខសង្គម | សមាជិក |
| ១០- **លោក កុយ ទេពដារាវុធ** | ប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១១- **លោក អ៊ុក ចាន់ធូ** | ប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១២- **លោក ឡេង តុង** | ប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ១៣- **លោក ឌី ស៊ីម៉ាណែត** | ប្រធាន ន. ផែនការ ស្ថិតិ និងនីតិកម្ម | សមាជិក |
| ១៤- **លោក ហៀង វាសនា** | ប្រធាន ន. សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៥- **លោក វ៉េង ហៀង** | ប្រធាននាយកដ្ឋានការងារកុមារ | សមាជិក |
| ១៦- **លោក ហែម ប៊ុននី** | ប្រធាន ន.ដ្ឋានមុខរបរ និងហត្ថពលកម្ម | សមាជិក |
| ១៧- **លោក ខៀវ សាវុធ** | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១៨- **លោក ហួន សឿរ** | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១៩- **លោក ខេង សំបូរ** | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ២០- **លោក តូច វុទ្ធី** | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ២១- **លោក ជ្រុន ថេរ៉ាវង្ស** | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |

| | | |
|---|---|---|
| ២២- **លោកស្រី មូ ច័ន្ទវាសនា** | អនុប្រធាននាយកដ្ឋានវិវាទការងារ សមាជិក | សមាជិក |
| ២៣- **លោកវេជ្ជ. ខុន ណារិទ្ធ** | អនុប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ២៤- **លោក ហេង សារឿន** | អនុប្រធាន ន. សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៥- **លោក ស៊ុំ សោភ័ណ** | នាយករងបេឡាជាតិរបបសន្តិសុខសង្គម | សមាជិក |
| ២៦- **លោក ពេជ្រ បញ្ញា** | ប្រធានការិ.គោលនយោបាយ និងនីតិកម្មកុមារ | សមាជិក |
| ២៧- **លោក ព្រុំ សុវណ្ណាក់** | អនុប្រធានការិ.អធិការកិច្ច និងសន្តិសុខការងារទី២ | សមាជិក |

ខ. តួនាទីភារកិច្ច ៖

- រៀបរៀងតាក់តែងខ្លឹមសារសេចក្តីព្រាងច្បាប់ស្តីពីតុលាការការងារ
- ពិភាក្សាផ្ទៃក្នុងលើខ្លឹមសារសេចក្តីព្រាងច្បាប់ស្តីពីតុលាការការងារ
- សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតុលាការការងារ
- សហការជាមួយដៃគូអភិវឌ្ឍ ដើម្បីធ្វើការស្រាវជ្រាវបទពិសោធន៍ច្បាប់ស្តីពីតុលាការការងារ ដើម្បីជាជំនួយស្មារតីក្នុងការកសាងច្បាប់នេះ ។
- ពិគ្រោះយោបល់ ដើម្បីប្រមូលយោបល់គ្រប់ភាគីធ្វើឱ្យសេចក្តីព្រាងច្បាប់ខាងលើនេះឱ្យមានភាពរលូនអាចទទួលយកបានទាំងអស់គ្នា និងអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាពខ្ពស់
- លើកវិធានការណ៍ជំរុញការកសាងច្បាប់ឱ្យបានឆាប់រហ័ស ទាន់ពេលវេលាជូនគណៈកម្មការ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល
- ទទួលភារកិច្ចផ្សេងៗទៀតដែលគណៈកម្មការប្រគល់ជូន។

**ប្រការ៣.-**

ត្រូវបានបង្កើតលេខាធិការដ្ឋានមួយសម្រាប់សម្រួលការងារដល់គណៈកម្មការរៀបចំយន្តការសម្រាប់កសាងសេចក្តីព្រាងច្បាប់ស្តីពីតុលាការការងារដែលមានសមាសភាព និងតួនាទីភារកិច្ចដូចខាងក្រោម៖

ក.សមាសភាព៖

| | | |
|---|---|---|
| ១- **ឯកឧត្តម ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | ប្រធាន |
| ២- **លោក ខឺ ស៊ីម៉ាណែត** | ប្រធាន ន. ផែនការ ស្ថិតិ និងនីតិកម្ម | អនុប្រធាន |
| ៣- **លោក ហាំង តុលា** | ប្រធាន ន. ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | អនុប្រធាន |
| ៤- **លោក ហៀង វាសនា** | ប្រធាន ន. សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥- **លោក គង់ ធារ័ត្ន** | ប្រធាន ន. រដ្ឋបាល និងបុគ្គលិក | សមាជិក |
| ៦- **លោក ហេង សារឿន** | អនុប្រធាន ន. សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៧- **កញ្ញា សុវណ្ណ វណ្ណារតន៍** | ទីប្រឹក្សាអមក្រសួង | សមាជិក |

ខ. តួនាទីភារកិច្ចៈ

- ចាត់ចែងផ្នែកហិរញ្ញវត្ថុ និងរៀបចំកិច្ចប្រជុំរបស់គណៈកម្មការ និងក្រុមការងារកសាងខ្លឹមសារ
- រៀបចំធ្វើកំណត់ហេតុ និងរបាយការណ៍ជូនគណៈកម្មការ
- ទទួលភារកិច្ចផ្សេងៗទៀតដែលគណៈកម្មការប្រគល់ជូន។

**ប្រការ៤.-**

ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចដឹកនាំជំនួសតាមការប្រគល់ជូនភារកិច្ចរបស់ប្រធាន ។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធានទីភ្នាក់ជាតិមុខរបរ និងការងារ ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានវិវាទការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធាននាយកដ្ឋានពេទ្យការងារ ប្រធាននាយកដ្ឋានការងារកុមារ ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

អ៊ិត សំហេង

<u>កន្លែងទទួល</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ